# ជំងឺបូសខ្យល់គោ-ក្របី



*រៀបរៀងដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម*
*អត្ថបទដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល*

## ជំងឺបូសខ្យល់ជាអ្វី ?

ជំងឺបូសខ្យល់ ជាជំងឺឆ្លងដ៏សាហាវបំផុត បង្កឡើងដោយ បាក់តេរី Clostridium Chauvei ដែលបង្កើតជាស្ព័រនៅក្នុង និង ក្រៅសារពាង្គកាយ បណ្ដាលឱ្យសត្វឈឺយ៉ាងឆាប់រហ័ស ហើយលក្ខណៈពិសេសនៃជំងឺ គឺ គ្រុនក្ដៅ ហើមក្នុងសាច់ដុំ ដែលបណ្ដាលមកពីខ្យល់ បង្កភាពគ្រោះថ្នាក់ដល់គោ-ក្របី និង ចៀម ។ ជំងឺនេះច្រើនកើតមាននៅដោយតំបន់ជាពិសេសកើត នៅរដូវភ្លៀងធ្លាក់ ដែលបណ្ដាលឱ្យសត្វស្លាប់យ៉ាងឆាប់រហ័យ ។

## មូលហេតុបង្កជំងឺ:

ជំងឺបូសខ្យល់ ជាជំងឺបង្កដោយបាក់តេរីឈ្មោះក្លូសទ្រី- ឌីយ៉ូមសូវេអ៊ី(Clostridium Chauvei) ដែលបង្កើតជាស្ព័រ ហើយស្ព័ររបស់វាធន់នឹងកំដៅ និងអាចរស់នៅបានយូរឆ្នាំ ក្នុងដី។

-ក្នុងលក្ខខណ្ឌ សមស្របវារស់នៅជាមធ្យមបានពី ៤-៥ ឆ្នាំ

-ក្នុងសាច់ធ្វើជាងៀតវាអាចរស់នៅបានយ៉ាងតិច ៨ ឆ្នាំ

-ក្នុងសាច់ប្រលាក់អំបិលវារស់នៅបាន ២ ឆ្នាំ

-ក្នុងសម្ភារៈ ឬ សំរាមស្អុយរលួយវារស់នៅបាន ៦ ខែ។

## តើជំងឺបូសខ្យល់រាលដាលដោយរបៀបណា ?

ជំងឺបូសខ្យល់ ឆ្លងពីសត្វមួយទៅសត្វមួយទៀតតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ។ មេរោគនៃជំងឺបូសខ្យល់ ចូលទៅក្នុងខ្លួនសត្វតាមរយៈការប៉ះពាល់ស្ព័រដែលមាននៅលើសាកសពសត្វផលិតផលសត្វឈឺលើដីលើស្មៅក្នុងទឹកឬតាមរយៈមុខរបួសផ្សេងៗ។

ជាញឹកញាប់គេពិនិត្យឃើញសត្វឆ្លងជំងឺតាមរយៈ

- ការស៊ីចំណី ឬ ផឹកទឹកជាមួយសត្វដែលឈឺ
- សាកសពនៃសត្វដែលស្លាប់ដោយជំងឺបូសខ្យល់ គឺ ជាប្រភពនៃការចម្លងជំងឺ
- ដី ដែលនៅជុំវិញកន្លែង ធ្វើការវះកាត់សាកសព នោះក្លាយទៅជាកន្លែងចម្លងមេរោគ ។

## រោគសញ្ញា:

ជំងឺបូសខ្យល់ភាគច្រើនកើតនៅលើគោអាយុចន្លោះពី ៦ ទៅ ៣ ឆ្នាំ ប៉ុន្តែជួនកាលសត្វដែលមានអាយុតិចជាង ឬ ច្រើនជាងនេះក៏អាចកើតមានដែរ ប្រសិនបើវានៅក្នុងហ្វូងជាមួយគ្នា។ ភាគច្រើនសត្វងាប់ដោយពុំមានបង្ហាញរោគសញ្ញាអ្វីឡើយរយៈពេលមេរោគសម្ងំមានពី ១-៥ ថ្ងៃ។

- សត្វមានអាការៈឡើងកំដៅ កម្លាំងចុះខ្សោយ ពិបាកដកដង្ហើម ដើរពចរដើរញាប់ និងពិបាកធ្វើចលនា។ សត្វមានការ

ហើមនៅតាមសាច់ដុំស្មា ត្រគាក ទ្រូង និងខ្នង។ ជាដំបូងយើងពិនិត្យឃើញនៅកន្លែងហើមនេះមានសភាពដុំតូច មានកំដៅ និង ឈឺចាប់។ មួយរយៈក្រោយមកដុំហើមនេះ រីកឡើងធំ ហើយបើយើងប៉ះត្រង់ដុំហើមនេះ វាមានសភាពត្រជាក់ គ្មានការឈឺចាប់ឡើយ និងមានសំឡេងលាន់ដូចមានខ្យល់នៅ ខាងក្នុង។ នៅលើមុខកន្លែងដុំហើមមានឡើងពណ៌ខ្មៅ ស្ងួតហើយមានក្លិនជូរ។ ក្រពេញកូនកណ្តុរនៅក្បែរៗ នោះក៏រីក ឡើងធំដែរ។

## វិធានការការពារ

- ចៀសវាងការប៉ះពាល់ផ្ទាល់ជាមួយនឹងសត្វឈឺ ឬ វត្ថុ ដែលមានប្រលាក់ប្រឡូសទៅដោយមេរោគ

-ត្រូវប្រញាប់រាយការណ៍ជូនមន្ត្រីបសុពេទ្យ ឬ ភ្នាក់ងារសុខភាពសត្វភូមិដែលនៅជិតអ្នកបំផុតនៅពេលមានសត្វឈឺ

- ត្រូវបំបែកសត្វឈឺចេញពីហ្វូង
- ត្រូវធ្វើអនាម័យកន្លែងចិញ្ចឹមជាប្រចាំ
- ជៀសវាងការផ្តល់ចំណី មានប្រភពពីកន្លែងផ្ទុះជំងឺ
- ហាមចលនាសត្វចេញ-ចូល ឆ្លងកាត់តំបន់ផ្ទុះជំងឺ
- ហាមទិញ-លក់សត្វគ្រប់ប្រភេទ ឬផលិតផលសត្វ ដែលមានជំងឺ ឬ ផ្ទុកមេរោគ
- សត្វងាប់ដោយជំងឺបូសខ្យល់ត្រូវដុតចោល ឬ កប់ក្នុងរណ្តៅដែលមានជម្រៅយ៉ាងតិច ២ម។

វិធានការដែលមានប្រសិទ្ធភាពបំផុត ក្នុងការការពារ កុំឱ្យគោ-ក្របីកើតជំងឺបូសខ្យល់គឺចាក់វ៉ាកសាំងការពារ។ ការចាក់



ស្នាមជាំឈាមខ្មៅនៅលើស្រទាប់ភ្នាសក្រោមស្បែក



ស្នាមជាំឈាមស្រទាប់ភ្នាសសាច់ដុំខាងក្រៅ និងក្នុង



ស្នាមជាំឈាមនៅលើសាច់ដុំ

វ៉ាក់សាំងត្រូវធ្វើឱ្យបានទៀងទាត់តាមប្រតិទិនចាក់ថ្នាំការពារចំពោះសត្វជិទង់ៗ ត្រូវចាក់ឱ្យបានពីរដងក្នុងមួឆ្នាំ។

- ចាក់លើកទី ១ នៅ អាយុពី ២- ៦ ខែ
- លើកទី ២ នៅក្រោយពេលចាក់លើកទីមួយបានពី ២-៤ អាទិត្យ
- បន្ទាប់មកត្រូវចាក់រៀងរាល់មួយឆ្នាំម្តង ។

---

## ការការពារប្រសើរជាងការព្យាបាល